# អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
# អគ្គនាយកដ្ឋានស្រាវជ្រាវ
# នាយកដ្ឋានស្រាវជ្រាវថវិកា

## ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

### មាតិកា៖

- CDC អនុម័តគម្រោងវិនិយោគចំនួន ១៥ ដែលមានទុនសរុបជាង ៥៤៩លានដុល្លារ
- ឧកញ៉ា ម៉ុង ឫទ្ធី នឹងចំណាយដើមទុនប្រមាណ ១០០លានដុល្លារក្នុងមួយឆ្នាំនៅក្នុងការវិនិយោគខ្សែសង្វាក់ផលិតកម្មរោងចក្រចំណីសត្វ
- រោងចក្រដំឡើងថយន្តថ្មីមួយទៀត ទទួលបានការអនុញ្ញាត គ្រោងបើកនៅខេត្តកោះកុង
- កម្ពុជារំពឹងទទួលបានកំណើនភ្ញៀវទេសចរកូរ៉េឡើងវិញ
- រាជរដ្ឋាភិបាលត្រៀមថវិកាជាង ២៥០ លានដុល្លារ ជួយវិស័យអាទិភាព ដោយយកការប្រាក់ទាប
- ពាណិជ្ជកម្មទំនិញសកល ថយល្បឿន ដោយសារបញ្ហាផ្គត់ផ្គង់ និងតម្រូវការនាំចូលថមថយ
- កម្ពុជាសង្ឃឹម លើការពិនិត្យវាយតម្លៃរបស់អាមេរិកអំពីសិទ្ធិទទួលបានប្រព័ន្ធអនុគ្រោះពន្ធGSP
- ការធ្លាក់ចុះកំណើនសេដ្ឋកិច្ចថៃទាបជាងការរំពឹងទុក ដោយសារទេសន្តរវិស័យសេដ្ឋកិច្ចក្នុងឆ្នាំ២០២១ រំពឹងថាវិស័យទេសចរណ៍នឹងងើបឡើងវិញ
- នាយកប្រតិបត្តិ JPMorgan លើកឡើងថា វិបត្តិបំណុលចិន ទំនងមិនជះឥទ្ធិពលទៅលើទីផ្សារពិភពលោក
- សេដ្ឋកិច្ចជប៉ុនធ្លាក់ចុះជាងការរំពឹងទុកដោយសារតែការផ្គត់ផ្គង់មានកង្វះខាត
- ប្រទេសផលិតមាសកំពូលទាំង១០ក្នុងលោក មាន១នៅអាស៊ាន


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គីម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### CDC អនុម័តគម្រោងវិនិយោគចំនួន១៥ ដែលមានទុនសរុបជាង ៥៤៩លានដុល្លារ




*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២១, រូបភាព៖ហេង ជីវ័ន*

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បានអនុម័ត គម្រោងវិនិយោគចំនួន ១៥ ដែលមានតម្លៃសរុប ៥៤៩,១ លានដុល្លារ និងបង្កើតការងារបានចំនួន ១៣ ៩៥២ កន្លែង នៅក្នុងរយៈពេល ២ សប្តាហ៍ដំបូងនៃខែវិច្ឆិកាឆ្នាំ ២០២១នេះ។

យោងតាមសេចក្តីប្រកាសព័ត៌មាន CDC គម្រោងវិនិយោគទាំង ១៥ មានគម្រោងធំៗមួយចំនួន ដូចជា៖ គម្រោងបង្កើតរោងចក្រផ្គុំ និងដំឡើងរថយន្តរបស់ក្រុមហ៊ុន R M A Automotive (Cambodia) Co., Ltd នៅស្រុកក្រគរ ខេត្តពោធិ៍សាត់ ទុនវិនិយោគ ២១ លានដុល្លារ, គម្រោងបង្កើតរោងចក្រផ្គុំដំឡើងគ្រឿងចក្ររថយន្តសណ្តោង និងរថយន្តដឹកទំនិញធុនធ្ងន់គ្រប់ប្រភេទរបស់ក្រុមហ៊ុន EM Automobile Co., Ltd នៅស្រុកស្រែអំបិល ខេត្តកោះកុង មានទុនវិនិយោគ ១៦,៣ លានដុល្លារ, គម្រោងសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនី ៥០០ គីឡូវ៉ុលពីបាត់ដំបងទៅព្រំដែនកម្ពុជា-ថៃរបស់ក្រុមហ៊ុន Schneitec Western Co., Ltd ទុនវិនិយោគ ១១១ លានដុល្លារ និងគម្រោងសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនី ៥០០ គីឡូវ៉ុលពីភ្នំពេញទៅព្រំដែនកម្ពុជា-ឡាវរបស់ក្រុមហ៊ុន Schneitec Northern Co., Ltd មានទុនវិនិយោគ ៣៣០ លានដុល្លារ។ ចំណែកគម្រោងផ្សេងទៀតរួមមានវិស័យកាត់ដេរ និងរោងចក្រកែច្នៃផ្លែឈើ រោងចក្រផលិតទឹកបរិសុទ្ធ ជាដើម។

អនុប្រធានសភាពាណិជ្ជកម្ម-កម្ពុជា លោក លឹម ហេង បានលើកឡើងថា៖ ការអនុម័តគម្រោង និងទុនវិនិយោគក្នុងចំនួនច្រើនបែបនេះ គឺបញ្ជាក់ពីទំនុកចិត្ត និងភាពរឹងមាំនៃទីផ្សារដែលវិនិយោគិនសម្លឹងឃើញពីការបណ្តាក់ទុននៅកម្ពុជា ខណៈកម្ពុជាជាប្រទេសមានស្ថិរភាពនយោបាយ កំណើនសេដ្ឋកិច្ចរឹងមាំ, ទំនាក់ទំនងការទូតល្អ, មានច្បាប់វិនិយោគថ្មីៗ, មានតំបន់សេដ្ឋកិច្ចពិសេសច្រើន និងមានប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធល្អប្រសើរ ព្រមទាំងមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទាំងទ្វេភាគី និងពហុភាគីត្រូវបានចុះហត្ថលេខាជាបន្តបន្ទាប់ជាមួយប្រទេសជាច្រើន ពិសេសប្រទេសចិន ដែលជាទីផ្សារមានប្រជាជនច្រើនជាងគេលើពិភពលោក។

បន្ថែមពីនេះ តួលេខនៃកំណើនវិនិយោគក៏ជាសូចនាករមួយក្នុងការបង្កើនភាពទាក់ទាញដល់អ្នកវិនិយោគផ្សេងទៀតឱ្យងាកមកចាប់អារម្មណ៍បណ្តាក់ទុនវិនិយោគនៅកម្ពុជា ជាពិសេសនាពេលនេះ គឺការចូលមកបណ្តាក់ទុនកាន់តែច្រើនលើឧស្សាហកម្មធុនមធ្យម និងធុន

ហើយចំនួននេះនឹងបន្តកើនឡើងទៀតចាប់ពីពេលនេះតទៅ ដែលវាបានចូលរួមចំណែកស្តារកំណើនសេដ្ឋកិច្ចជាតិក្នុង និងក្រោយវិបត្តិជំងឺកូវីដ ១៩។

ក្រៅពីនេះ ការប្រកាសបើកសកម្មភាពសេដ្ឋកិច្ច និងសង្គមស្ទើរទាំងស្រុងឡើងវិញពីសំណាក់ប្រមុខរដ្ឋាភិបាល ចាប់ពីថ្ងៃទី ១៥ ខែវិច្ឆិកា ក៏ជាកម្លាំងចលករបន្ថែមទៀតដែលនឹងធ្វើឱ្យវិនិយោគិនកាន់តែច្រើនបញ្ចេញទុននៅកម្ពុជា។

យោងតាមការគណនារបស់ភ្នំពេញប៉ុស្តិ៍ ក្នុងរយៈពេល ៦ខែ (មករា-មិថុនា) ឆ្នាំ២០២១នេះ CDC បានអនុម័តគម្រោងចំនួន ៧០ ដែលមានទុនវិនិយោគសរុបចំនួន ២ ៤២៨លានដុល្លារ ដែលភាគច្រើនជាគម្រោងវិនិយោគក្នុងវិស័យវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ ស្បែកជើង ផលិតផលធ្វើដំណើរ គ្រឿងផ្គុំអគ្គិសនី គ្រឿងផ្គុំទោចក្រយាន គ្រឿងសង្ហារិម វិស័យថាមពលអគ្គិសនី និងបដិសណ្ឋារកិច្ចជាដើម ។ *មុំ ចិន្តា*

*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១*

## ឧកញ៉ា ម៉ុង ឫទ្ធី នឹងចំណាយដើមទុនប្រមាណ ១០០ លានដុល្លារក្នុងមួយឆ្នាំ នៅក្នុងការវិនិយោគខ្សែសង្វាក់ផលិតកម្មរោងចក្រចំណីសត្វ



*ដោយ ខេមបុណ្ណមីស*

ឯកឧត្តម ឧកញ៉ា បណ្ឌិត ម៉ុង ឫទ្ធី ថ្មីៗនេះ បានបោះទុនវិនិយោគ ពង្រីកផលិតកម្មចំណីសត្វនៅកម្ពុជា លើផ្ទៃដីរោងចក្រទាំងមុន និងក្រោយសរុបប្រមាណ ១៥ ហិកតា។ ក្រោយពីរោងចក្រនេះ ដាក់ឱ្យដំណើរការ ទាំងទុនវិនិយោគ និងទុនបង្វិល ត្រូវចំណាយថវិកាយ៉ាងហោចណាស់ប្រមាណ ១០០លានដុល្លារក្នុងមួយឆ្នាំ។ រោងចក្រនេះ អាចជួយបង្កើតទីផ្សារកសិផលខ្មែរ ដូចជា ពោតក្រហម ដំឡូងមី និងកន្ទក់ និងជួយផ្គត់ផ្គត់ចំណីសត្វសម្រាប់ទីផ្សារក្នុងស្រុក ព្រោះកម្ពុជា មិនទាន់មានលទ្ធភាពគ្រប់គ្រាន់ ក្នុងការផ្គត់ផ្គង់ផលិតផលចំណីសត្វនៅឡើយ។

រោងចក្រផលិតចំណីសត្វទី២របស់ក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប មានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ ភូមិមនោរម្យ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ហើយមានកម្លាំងផលិត៣០តោនក្នុងមួយម៉ោង គិតជាមធ្យមគឺ ១៨ ០០០តោនក្នុងមួយខែ។ រោងចក្រនេះនឹងត្រូវសាងសង់រួចរាល់នាដើមឆ្នាំ២០២៣ខាងមុខ។ ដោយឡែក រោងចក្រទី១ ដែលកំពុងដំណើរការបានប្រមូលទិញកសិផលពីប្រជាកសិករអស់រយៈពេល៤ឆ្នាំកន្លងមកហើយ។

នៅពេលរោងចក្រផលិតចំណីសត្វថ្មីនេះសាងសង់រួចរាល់ កសិករនឹងមានទីផ្សារលក់កសិផលសរុបជាមួយរោងចក្រទាំងពីរនេះដោយមិនចាំបាច់ដឹកឆ្លងដែនយកទៅលក់នៅឯបរទេសទៀតទេ។

ឯកឧត្តម ឧកញ៉ា បណ្ឌិត បានមានប្រសាសន៍ថា ការផលិតចំណីសត្វនេះ គឺមិនសម្រាប់នាំចេញទៅក្រៅប្រទេសនោះទេ គឺគ្រាន់តែផ្គត់ផ្គង់កសិដ្ឋានផ្ទាល់ឱ្យបានគ្រប់គ្រាន់តាមតម្រូវការ។ *ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបុណ្ណមីស ចេញផ្សាយថ្ងៃទី១៤ខែវិច្ឆិកា ឆ្នាំ២០២១។*

## រោងចក្រដំឡើងរថយន្តថ្មីមួយទៀត ទទួលបានការអនុញ្ញាតគ្រោងបើកនៅខេត្តកោះកុង




ដោយ Kampucheathmey

គណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានសម្រេចចេញវិញ្ញាបនបត្រចុះបញ្ជីជាស្ថាពរ ជូនដល់ក្រុមហ៊ុន EM AUTOMOBILE CO., LTD លើគម្រោងបង្កើតរោងចក្រផ្គុំដំឡើងគ្រឿងចក្រ រថយន្តសណ្តោង និងរថយន្តដឹកទំនិញធុនធ្ងន់គ្រប់ប្រភេទ នៅស្រុកស្រែអំបិលខេត្តកោះកុង ដែលមានទីតាំងវិនិយោគស្ថិតនៅផ្លូវជាតិលេខ៤៨ ភូមិឈូក ឃុំដីឥដ្ឋលើ ស្រុកស្រែអំបិល ខេត្តកោះកុង។ គម្រោងនេះប្រើទុនវិនិយោគចំនួន ១៦,៣លានដុល្លារអាមេរិក និងអាចបង្កើតការងារបានចំនួន ៥១៥កន្លែង៕

ដូចគ្នាដែរនៅខេត្តពោធិ៍សាត់ ក៏មានក្រុមហ៊ុន R M A AUTOMOTIVE (CAMBODIA) បាន និងកំពុងដំណើរការបង្កើតរោងចក្រផ្គុំ និងដំឡើងរថយន្ត ដែលមានទីតាំងវិនិយោគស្ថិតនៅផ្លូវជាតិលេខ៥ ភូមិសារវ៉ែន ឃុំស្នាអន្សា ស្រុកក្រគរ មានទុនវិនិយោគចំនួន ២១លានដុល្លារអាមេរិក។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖Kampucheathmey ចេញផ្សាយថ្ងៃទី១២ខែវិច្ឆិកា ២០២១។*

## កម្ពុជារំពឹងទទួលបានភ្ញៀវទេសចរកូរ៉េឡើងវិញ



*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២១ រូបភាព៖ ហេង ជីវ៉ន*

ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍កម្ពុជា បានជួបពិភាក្សាការងារជាមួយ លោក Park Heung-Kyeong ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា នៅទីស្តីការក្រសួងទេសចរណ៍កាលពីពេលថ្មីៗនេះ ។ លោក Park Heung-Kyeong បានប្រកាសគាំទ្រចំពោះគំនិតផ្តួចផ្តើមរបស់កម្ពុជាលើការបើកទទួលទេសចរអន្តរជាតិចាក់វ៉ាក់សាំងពេញលេញ និងបានសន្យាជួយជំរុញភ្ញៀវទេសចរកូរ៉េមកទស្សនាកម្ពុជាបន្ថែមទៀត ដោយសារប្រជាពលរដ្ឋនៃប្រទេសទាំងពីរមានអត្រាខ្ពស់ក្នុងការទទួលបានការចាក់វ៉ាក់សាំងពេញលេញដូចគ្នា។

កន្លងមកកម្ពុជាទទួលភាពជោគជ័យពីការបើកទេសចរណ៍ ផ្ទៃក្នុង លទ្ធផលនៃការបើកទេសចរណ៍ផ្ទៃក្នុង គឺជាការដកបទពិសោធក្នុងការបើកទទួលទេសចរអន្តរជាតិពេញលេញ តាមរយៈការដាក់ចេញនូវផែនទីចង្អុលផ្លូវស្តីពីការលើកកម្ពស់ និងការស្តារវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិកូវីដ-១៩ ក្នុងនោះរួមមាន(ការដាក់ចេញផែនការមេ និងយុទ្ធសាស្ត្រថ្មីជាច្រើន) ស្របពេលដែលបច្ចុប្បន្នប្រជាជនទូទាំងប្រទេសកម្ពុជាបានសម្រេចចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ បានជាង ៨០%។

កម្ពុជាគ្រោងនឹងទទួលទេសចរអន្តរជាតិចាក់វ៉ាក់សាំងគ្រប់ចំនួនលើកដំបូងនៅក្រុងព្រះសីហនុ ក្រុងកោះរ៉ុង និងតំបន់តាពាសាគរខេត្តកោះកុង ចាប់ពីថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ ២០២១ បន្ទាប់មកនឹងបន្តទៅសៀមរាបអង្គរនៅខែមករា ឆ្នាំ ២០២២។

លោក ធួន ស៊ីណាន ប្រធានសមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិកកម្ពុជា បានលើកឡើងថា ភ្ញៀវទេសចរកូរ៉េចូលចិត្តមកទស្សនានៅតំបន់ប្រាសាទ និងធម្មជាតិនៅកម្ពុជា ហើយការស្នាក់នៅរបស់ពួកគេគឺភាគច្រើនចន្លោះពី ៣-៥ យប់ គឺប្រហាក់ប្រហែលនឹងភ្ញៀវជនជាតិជប៉ុន។ ទេសចរកូរ៉េ គឺមិនដូចនឹងភ្ញៀវទេសចរពីតំបន់អឺរ៉ុបនោះទេដោយពួកគេចូលចិត្តប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន ឬមគ្គុទ្ទេសក៍ជនជាតិកូរ៉េផ្ទាល់តែម្តងដែលមិនបានផ្តល់ចំណូលផ្ទាល់ដល់មគ្គុទ្ទេសក៍របស់ក្រុមហ៊ុនក្នុងស្រុក ប៉ុន្តែវិស័យសណ្ឋាគារ កន្លែងលក់ទំនិញ និងហាងលក់អាហារនៅតែអាចបានទទួលអត្ថប្រយោជន៍ច្រើនសម្រាប់ជួយដល់កំណើនសេដ្ឋកិច្ចជាតិ។

ទិន្នន័យក្រសួងទេសចរណ៍បានបង្ហាញថា ចាប់ពីខែមករាដល់ខែកក្កដា ឆ្នាំ ២០២១ ភ្ញៀវទេសចរកូរ៉េធ្វើដំណើរមកកម្ពុជា មានចំនួន ២ ១៧១ នាក់ ធ្លាក់ចុះ ៩៥,៩ % ។ ៕*ដោយ សេន ចន្ទ*

*ប្រភព៖ [ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០២១]*

## រាជរដ្ឋាភិបាលត្រៀមថវិកាជាង ២៥០ លានដុល្លារ ជួយវិស័យអាទិភាព ដោយយកការប្រាក់ទាប



*ដោយ Kampucheathmey*

រាជរដ្ឋាភិបាល នឹងដាក់ចេញនូវយន្តការហិរញ្ញប្បទានដល់វិស័យឯកជន ដោយបានត្រៀមថវិកាប្រមាណ ២៥០ លានដុល្លារអាមេរិកនៅឆ្នាំ២០២២ សម្រាប់ផ្តល់ឥណទាន ដោយត្រង់ទៅធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា និងធនាគារអភិវឌ្ឍជនបទ និងកសិកម្ម ក្នុងអាត្រាការប្រាក់ទាបក្នុងរង្វង់៥%ទៅ ៥,៥%សម្រាប់វិស័យសំខាន់ៗ។

រាជរដ្ឋាភិបាលនឹងផ្តោតជាចម្បងក្នុងការដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ (structural issues) ក្នុងវិស័យដែលនៅមានសក្តានុពល និងជាចន្ទល់កំណើនសេដ្ឋកិច្ច ដែលអាចបង្កើតនូវតម្លៃបន្ថែមក្នុងរយៈពេលខ្លី(២០២១-២០២៣) និងជំរុញការងើបឡើងវិញសកម្មភាពសង្គម-សេដ្ឋកិច្ចជាតិ ទៅរកប្រក្រតីភាពថ្មីឱ្យបានឆាប់រហ័ស រួមមានបួនគឺ វិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម វិស័យទេសចរណ៍ វិស័យកាត់ដេរ និងវិស័យកម្មនសាលមិនមែនកាត់ដេរ។

រាជរដ្ឋាភិបាល នឹងផ្តោតជាអាទិភាពលើគោលនយោបាយកម្មវិធី និងវិធានការចម្បងៗក្នុងនោះ ក៏មានរៀបចំយន្តការលើកលែង ឬព្យួរអាករលើតម្លៃបន្ថែម (VAT) និងពន្ធនាំចូល (Tariff) លើសម្ភារៈសម្រាប់សាងសង់ផ្ទះកញ្ចក់ សំណាញ់ ទុយោតំណក់

ទឹក ទុយោបាចសាច បំពង់ទឹបដំរ ដែលបម្រើដល់ការដាំដុះបន្លែ សម្ភារៈ គ្រឿងចក្រ គ្រឿងម៉ាស៊ីន និងឧបករណ៍បម្រើឱ្យការផលិត ការកែច្នៃ និងការផ្គត់ផ្គង់ផលិតផលកសិកម្ម រម្ងាប់ដង្កូវរុយចោះផ្លែស្វាយ និងមៀនប៉ៃលិន មាស៊ីនសម្រាប់បំពាក់ក្នុងបន្ទប់ត្រជាក់ផ្ទុកស្វាយស្រស់ (Chiller Machine) ប្រព័ន្ធកង្ហាត្រជាក់បំពាក់រោងចិញ្ចឹមសត្វ និងប្រព័ន្ធដាក់ចំណីសត្វស្វ័យប្រវត្តិ។ ជំរុញការវិនិយោគឯកជនលើប្រព័ន្ធដឹកជញ្ជូនត្រជាក់ តាមរយៈយន្តការនៃការលើកលែង ឬពន្យរពន្ធនាំចូល និងអាករលើតម្លៃបន្ថែម សម្រាប់ទូកុងតឺន័រត្រជាក់ ដែលប្រើប្រាស់សម្រាប់ការដឹកជញ្ជូនផ្លែចេកអំបូងលឿង និងស្វាយស្រស់ ទៅទីផ្សារអន្តរជាតិ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖Kampucheathmeyចេញផ្សាយថ្ងៃទី ថ្ងៃ១៦ខែវិច្ឆិកាឆ្នាំ២០២១*

# តារាងប្រចាំសប្តាហ៍

## តារាងទី១ ៖ ពាណិជ្ជកម្មរវាងកម្ពុជា និងប្រទេសថៃលើមុខទំនិញ នៅក្នុងខែកញ្ញា ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ធនាគារជាតិប្រទេសថៃ បានបង្ហាញថា នៅក្នុងខែកញ្ញាឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងប្រទេសថៃ ដែលមានទំហំទឹកប្រាក់សរុប ៧៣២,៤២លានដុល្លារ មានកំណើនប្រមាណជា ១៧,១% បើធៀបនឹងខែសីហានៃឆ្នាំដដែល។

ជាក់ស្តែង ការនាំចេញទំនិញរបស់កម្ពុជាទៅប្រទេសថៃ មានទំហំទឹកប្រាក់ប្រមាណជា ៦៣, ៧៩លានដុល្លារ នៅក្នុងខែ កញ្ញាឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា ៦៣,៧៩% បើធៀបនឹងខែសីហា ឆ្នាំ២០២១។

ដោយឡែក ការនាំចូលទំនិញរបស់ប្រទេសថៃមកកម្ពុជា មានទំហំទឹកប្រាក់ ៦៦៨,៦៣លានដុល្លារ នៅក្នុងខែកញ្ញា ឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា ១៧,១% បើធៀបនឹងខែសីហា ឆ្នាំ២០២១។ ដោយ មិត្ត ចន្ទី

***ឯកតា៖ គិតជាលានដុល្លារអាមេរិក***

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា |
|---|---|---|---|---|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | **653.39** | **644.76** | **799.19** | **596.61** | **671.83** | **616.20** | **630.47** | **625.27** | **732.42** |
| កំណើន% | | -1.3% | 24.0% | -25.3% | 12.6% | -8.3% | 2.3% | -0.8% | 17.1% |
| កម្ពុជានាំចេញទៅថៃ | 113.22 | 112.05 | 104.27 | 72.63 | 57.65 | 55.93 | 52.97 | 54.51 | 63.79 |
| កំណើន% | | -1.0% | -6.9% | -30.3% | -20.6% | -3.0% | -5.3% | 2.9% | 17.0% |
| ថៃនាំចូលមកកម្ពុជា | 540.17 | 532.71 | 694.92 | 523.98 | 614.18 | 560.27 | 577.50 | 570.76 | 668.63 |
| កំណើន% | | -1.4% | 30.4% | -24.6% | 17.2% | -8.8% | 3.1% | -1.2% | 17.1% |

ប្រភព៖ *ធនាគារជាតិប្រទេសថៃ*

## តារាងទី២ ៖ ការចំណាយលើអត្ថប្រយោជន៍សង្គមប្រចាំខែសីហា ឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា នៅក្នុងខែសីហាឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិបានចំណាយលើអត្ថប្រយោជន៍សង្គម ក្នុងទំហំទឹកប្រាក់សរុបចំនួន ៣៦៤,០៤ប៊ីលានរៀល ដែលមានការធ្លាក់ចុះប្រមាណជា ២៤,១%បើធៀបនឹងខែកក្កដា នៃឆ្នាំ២០២១។

ជាក់ស្តែង ការចំណាយលើអត្ថប្រយោជន៍សន្តិសុខសង្គម មានទឹកប្រាក់ចំនួន ៩៤,៥៩ប៊ីលានរៀល នៅក្នុងខែសីហាឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា ៥,២% បើធៀបនឹងខែកក្កដា ឆ្នាំ២០២១។

ទន្ទឹមនឹងនោះដែរ ការចំណាយលើជំនួយសង្គមដល់ប្រជាពលរដ្ឋ មានទឹកប្រាក់ចំនួន២៥៧,៧០ប៊ីលានរៀល នៅក្នុងខែមិថុនាឆ្នាំ២០២១ មានការធ្លាក់ចុះប្រមាណជា ៤,១% បើធៀបនឹងខែកក្កដា ឆ្នាំ២០២១។

ក៏ប៉ុន្តែ ការចំណាយលើអំណោយពីពហុភាគីសំរាប់ចំណាយវិនិយោគ មានទំហំទឹកប្រាក់៨,៩៤ប៊ីលានរៀល នៅក្នុងខែសីហា ឆ្នាំ២០២១ មានកំណើនប្រមាណជា ១៨% បើធៀបនឹងខែឧសភា។

ដោយឡែក ការចំណាយអត្ថប្រយោជន៍សង្គមផ្សេងៗទៀត មានទឹកប្រាក់ចំនួន ២,៨១ប៊ីលានរៀល នៅក្នុងខែសីហាឆ្នាំ២០២១នេះ៕ ដោយ មិត្ត ចន្ទី

ប្រភព៖[តារាងប្រតិបត្តិការហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ខែសីហាឆ្នាំ២០២១]

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### តារាងប្រៀបធៀបចំណូលថវិការដ្ឋរបស់ប្រទេសម៉ាឡេស៊ី ២០២០-២០២២

| ចំណូល (គិតជាប៊ីលានរីងហ្គីត) | | | | ចំណែក(%) | | | កំណើន | |
|---|---|---|---|---|---|---|---|---|
| | 2020 | 2021 | 2022 | 2020 | 2021 | 2022 | 2021 | 2022 |
| **ចំណូលសរុប** | **225,076** | **221,023** | **234,011** | **100%** | **100%** | **100%** | -1.8% | 5.9% |
| **ចំណូសារពើពន្ធ** | **154,398** | **161,830** | **171,374** | **69%** | **73%** | **73%** | 4.8% | 5.9% |
| **ពន្ធផ្ទាល់** | **112,511** | **120,048** | **127,334** | **50%** | **54%** | **54%** | 6.7% | 6.1% |
| ពន្ធលើប្រាក់ចំណេញ | 104,884 | 111,810 | 118,722 | **47%** | **51%** | **51%** | 6.6% | 6.2% |
| ពន្ធផ្សេងៗ | 7,627 | 8,237 | 8,611 | **3%** | **4%** | **4%** | 8.0% | 4.5% |
| **ពន្ធប្រយោល** | **41,887** | **41,782** | **44,040** | **19%** | **19%** | **19%** | -0.3% | 5.4% |
| ពន្ធនាំចេញ | 746 | 1,406 | 1,610 | **0%** | **1%** | **1%** | 88.4% | 14.5% |
| ពន្ធនាំចូល | 2,346 | 2,330 | 2,500 | **1%** | **1%** | **1%** | -0.7% | 7.3% |
| ពន្ធលើទំនិញក្នុងស្រុក | 4,719 | 3,640 | 3,804 | **2%** | **2%** | **2%** | -22.9% | 4.5% |
| អាករលើផលរបរ( sale tax local ) | 6,494 | 5,306 | 5,425 | **3%** | **2%** | **2%** | -18.3% | 2.2% |
| អាករលើផលរបរ( sale tax import | 8,273 | 8,935 | 9,135 | **4%** | **4%** | **4%** | 8.0% | 2.2% |
| ពន្ធលើសេវាកម្ម( service tax ) | 12,006 | 12,287 | 13,000 | **5%** | **6%** | **6%** | 2.3% | 5.8% |
| ពន្ធផ្សេងៗ | 7,303 | 7,878 | 8,566 | **3%** | **4%** | **4%** | 7.9% | 8.7% |
| **ចំណូលមិនមែនសារពើពន្ធ** | **70,678** | **59,193** | **62,637** | **31%** | **27%** | **27%** | **-16.2%** | **5.8%** |
| អាជ្ញាប័ណ្ណ និងការអនុញ្ញាត | 10,932 | 10,252 | 10,958 | **4.9%** | **5%** | **5%** | **-6.2%** | **6.9%** |
| ប្រាក់ចំណូលវិនិយោគ | 46,067 | 35,989 | 39,457 | **20.5%** | **16%** | **17%** | **-21.9%** | **9.6%** |

*ប្រភព៖ [ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ម៉ាឡេស៊ី]*

### កម្ពុជា ចិនឯកភាពគ្នាជំរុញពាណិជ្ជកម្មប្រទេសទាំងពីរឱ្យកើនឡើងដល់១០ពាន់លានដុល្លារក្នុងមួយឆ្នាំ



*ប្រភព៖ SPM*

កម្ពុជា និងចិនបានឯកភាពគ្នាក្នុងការជំរុញពាណិជ្ជកម្មប្រទេសទាំងពីរឱ្យកើនឡើងដល់ ១០ពាន់លានដុល្លារក្នុងមួយឆ្នាំ។ ភាគីចិន នឹងបន្តផ្តល់ជូនកម្ពុជានូវវ៉ាក់សាំងដើម្បីជួយទប់ស្កាត់ជំងឺកូវីដ១៩ និងជំនួយពាក់ព័ន្ធនឹងវិស័យសុខាភិបាល នឹងផ្តល់អាហារូបករណ៍ដល់កម្ពុជាសម្រាប់ឆ្នាំ២០២២-២០២៣ ចំនួន ៥៥០ អាហារូបករណ៍ និងក៏ពិចារណាបើកឱ្យនិស្សិតកម្ពុជាត្រឡប់ទៅសិក្សានៅចិនវិញ។ ភាគីចិន នឹងចូលរួមប្រជុំអាស៊ី-អឺរ៉ុបនាពេលខាងមុខ និងគាំទ្រកម្ពុជាពេលធ្វើជាប្រធានអាស៊ាន ឆ្នាំ២០២២។
ប្រមុខរាជរដ្ឋាភិបាល បានអបអរសាទរចំពោះកំណើនសេដ្ឋកិច្ចចិន ៩,៨% សម្រាប់ ៩ខែដំបូង នៅឆ្នាំ២០២១។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ khmerfirst ចេញផ្សាយថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។*

### កម្ពុជាសង្ឃឹម លើការពិនិត្យវាយតម្លៃរបស់អាមេរិកអំពីសិទ្ធិទទួលបានប្រព័ន្ធអនុគ្រោះពន្ធGSPសម្រាប់កម្ពុជា



*ដោយ ខេមបូណូមីស*

សហរដ្ឋអាមេរិក នឹងធ្វើការពិនិត្យវាយតម្លៃឡើងវិញក្នុងការផ្តល់នូវភាពអនុគ្រោះពន្ធ GSP បន្តទៀតមកឱ្យកម្ពុជា ខណៈប្រព័ន្ធអនុគ្រោះពន្ធនេះ ត្រូវបានផុតសុពលភាពតាំងពីចុងឆ្នាំ២០២០មកម្ល៉េះ។ កន្លងមក ស្ថានទូតកម្ពុជា បានចូលរួមជាមួយប្រទេសសមាជិកសម្ព័ន្ធនៃប្រព័ន្ធអនុគ្រោះពន្ធ GSP សរុបមាន ២៧ប្រទេស ហើយ

ប្រទេសទាំងនេះបានចុះហត្ថលេខាលើលិខិតរួមចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១ ស្នើសុំជំរុញឱ្យសភាអាមេរិកបន្តកម្មវិធីប្រព័ន្ធអនុគ្រោះពន្ធទូទៅGSPនេះ។ នេះជាការចូលរួមលើកទី២នៃប្រទេសសមាជិកសម្ព័ន្ធនៃប្រព័ន្ធអនុគ្រោះពន្ធ GSP (Alliance of GSP Countries)។ កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ មានក្រុមហ៊ុន និងសមាគមន៍ពាណិជ្ជកម្ម អាមេរិកជាង ៣០០ បានចុះហត្ថលេខាលើលិខិតរួមគ្នាផ្ញើជូនសមាជិកជាន់ខ្ពស់នៃសភាអាមេរិក ជំរុញឱ្យសភាសហរដ្ឋអាមេរិកបន្តកម្មវិធីប្រព័ន្ធអនុគ្រោះពន្ធទូទៅ GSP ឡើងវិញឱ្យបានឆាប់រហ័ស ព្រមទាំងជំរុញឱ្យសភាសហរដ្ឋអាមេរិក ចាត់ទុកការបន្តកម្មវិធីនេះ ជាការងារអាទិភាពរបស់សភាអាមេរិក។

បើតាមការលើកឡើងរបស់ក្រសួងការបរទេសអាមេរិក តំណាងពាណិជ្ជកម្មសហរដ្ឋអាមេរិកនឹងធ្វើការវាយតម្លៃលើសិទ្ធិទទួលបានប្រព័ន្ធអនុគ្រោះទូទៅ (GSP) របស់កម្ពុជា ដែលជាផ្នែកមួយនៃការវាយតម្លៃ GSP ទូលំទូលាយ។

អ្នកនាំពាក្យក្រសួងពាណិជ្ជកម្មកម្ពុជា បានលើកឡើងថា កម្ពុជា មានក្តីសង្ឃឹមពីការពិនិត្យវាយតម្លៃក្នុងការបន្តផ្តល់ប្រព័ន្ធអនុគ្រោះពន្ធ GSPនេះ ដោយសារតែ អាមេរិកមានទំនាក់ទំនងល្អ និងឆន្ទៈល្អ ចំពោះប្រទេសមានការអភិវឌ្ឍតិចតួច(LDCs)។

ប្រព័ន្ធអនុគ្រោះពន្ធGSPដែលអាមេរិកបានផ្តល់ជូនកម្ពុជានាពេលកន្លងមកនេះ បានផ្តល់នូវអត្ថប្រយោជន៍ច្រើនសម្រាប់កម្ពុជានាំចេញទំនិញទៅកាន់សហរដ្ឋអាមេរិក ខណៈដែលកាលពីឆ្នាំ២០២០ ការនាំចេញទំនិញរបស់កម្ពុជាទៅអាមេរិកមានជាង ៦ពាន់៦រយលានដុល្លារ ក្នុងនោះ មានប្រមាណ២ពាន់លានដុល្លារអាមេរិក គឺបាននាំចេញក្រោមប្រព័ន្ធអនុគ្រោះពន្ធ GSPនេះ។ សហរដ្ឋអាមេរិក គឺជាទីផ្សារធំបំផុតទី២ របស់កម្ពុជា បន្ទាប់ពីអឺរ៉ុបសម្រាប់ការនាំចេញទំនិញ ហើយការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារធំៗទាំងពីរនេះ នាពេលកន្លងមកក៏មានការអនុគ្រោះពន្ធជាច្រើនផងដែរ។ តាមរបាយការណ៍ធនាគារពិភពលោក ការនាំចេញផលិតផលកាត់ដេរ ស្បែកជើង និងផលិតផលធ្វើដំណើរពីកម្ពុជាទៅអាមេរិកនៅឆ្នាំ២០២០មានការកើនឡើង ៤% បើទោះបីជាមានបញ្ហាកូវីដ១៩ក៏ដោយ ខណៈដែលការនាំចេញទៅអឺរ៉ុបវិញធ្លាក់ចុះ៣៥%។

*ដោយ ម៉ែន ខេមរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី១៥ខែវិច្ឆិកា ឆ្នាំ២០២១។*

## ការធ្លាក់ចុះកំណើនសេដ្ឋកិច្ចថៃទាបជាងការរំពឹងទុក ដោយសារទស្សនៈវិស័យសេដ្ឋកិច្ចក្នុងឆ្នាំ២០២១ រំពឹងថាវិស័យទេសចរណ៍នឹងងើបឡើងវិញ



*បុគ្គលិកកំពុងរៀបចំបើកភោជនីយដ្ឋានឡើងវិញនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ ប្រភព៖ Reuters*

កំណើនសេដ្ឋកិច្ចរបស់ថៃធ្លាក់ចុះទាបជាងការរំពឹងទុកនៅក្នុងត្រីមាសទី៣ ក្នុងឆ្នាំ២០២១ នេះ ដោយសារតែវិស័យពាណិជ្ជកម្មចាប់ផ្តើមមានសកម្មភាពឡើងវិញ ខណៈដែលវិស័យទេសចរណ៍រំពឹងថា នឹងល្អប្រសើរឡើងវិញ។ រដ្ឋាភិបាលថៃបានធ្វើបច្ចុប្បន្នភាពកំណើនសេដ្ឋកិច្ចរបស់ខ្លួនសម្រាប់ឆ្នាំនេះចំនួន ១,២% កើន

ឡើងជាងការព្យាករណ៍ដែលរំពឹងថា នឹងកើនឡើងត្រឹមចន្លោះពី ០,៧% ទៅ ១,២% ធៀបទៅនឹងការព្យាករណ៍កាលពីលើកមុន និងបានព្យាករណ៍កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២២ ថាអាចនឹងមានកំណើនក្នុងរង្វង់ពី ៣,៥% ទៅ ៤,៥% ដោយសារតែការរឹតបន្តឹងលើវិធានការទប់ស្កាត់កូវីដ១៩ មានភាពធូរស្រាលជាងមុន និងដោយសារប្រទេសថៃចាប់ផ្តើមបើកឱ្យអ្នកដំណើរចូលមកកាន់ប្រទេសរបស់ខ្លួនវិញ ដើម្បីជំរុញឧស្សាហកម្មទេសចរណ៍។

គួររំលឹកថា កាលពីឆ្នាំ២០២០ កំណើនសេដ្ឋកិច្ចធំជាងគេលំដាប់ទីពីរនៅអាស៊ីអាគ្នេយ៍មួយនេះធ្លាក់ចុះនៅត្រឹម៦,១%។

NESDC រំពឹងថា ការនាំចេញនៅក្នុងឆ្នាំ២០២១ នឹងមានកំណើន ១៦,៨% ហើយនឹងកើនដល់ ១៦,៣% ក្នុងឆ្នាំ២០២២។ ទីភ្នាក់ងារទេសចរណ៍បានព្យាករណ៍ថា នឹងមានភ្ញៀវទេសចរណ៍បរទេសចូលមកប្រទេសថៃចំនួន ២០០ ០០០ នាក់ក្នុងឆ្នាំ២០២១ នេះ និងបានព្យាករណ៍ថានឹងមានភ្ញៀវទេសចរណ៍ ៥លាននាក់នៅក្នុងឆ្នាំ២០២២។ គួររំលឹកថា កាលពីឆ្នាំ២០១៩ ថៃទទួលភ្ញៀវទេសចរណ៍៤០លាននាក់។

ទោះយ៉ាងណាក៏ដោយ ទោះបីជាវិស័យទេសចរណ៍ស្ទុះងើបឡើងវិញយ៉ាងឆាប់រហ័សក្តី អ្នកវិភាគមួយចំនួនយល់ឃើញថា ការស្ទុះងើបឡើងវិញនៃសេដ្ឋកិច្ចរបស់ថៃអាចនឹងមានភាពយឺតយ៉ាវ ប្រសិនបើប្រៀបធៀបទៅនឹងចំនួនភ្ញៀវទេសចរណ៍របស់ថៃមុនពេលមានកូវីដ១៩។ ទោះយ៉ាងណារដ្ឋាភិបាលថៃបានបញ្ចេញទឹកប្រាក់រាប់ប៊ីលានដុល្លារ ដើម្បីបន្ធូរបន្ថយវិធានការរដ្ឋបាលក្នុងគោលដៅស្តារសេដ្ឋកិច្ចឡើងវិញ ខណៈដែលធនាគារកណ្តាលបានកាត់បន្ថយអត្រាការប្រាក់ក្នុងកម្រិតទាបបំផុតនៅត្រឹម ០,៥០% ចាប់តាំងពីខែឧសភា ឆ្នាំ២០២០ មកម្លេះ។ *ដោយ **កញ្ញា វង្ស ច័ន្ទរស្មីដារា***

*ប្រភព៖ Reuters ចេញផ្សាយ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### ពាណិជ្ជកម្មទំនិញសកល ថយល្បឿន ដោយសារបញ្ហាផ្គត់ផ្គង់ និងតម្រូវការនាំចូលថមថយ



*ប្រភព៖ Reuters, រូបភាព៖ Aly Song*

អង្គការពាណិជ្ជកម្មពិភពលោក បង្ហាញថា កំណើនពាណិជ្ជកម្មសកល បានកំពុងនឹងថយល្បឿន ដោយសារតែការរំខានផ្នែកផលិតកម្ម និងផ្គត់ផ្គង់ ក៏ដូចជាការថមថយនៃតម្រូវការនាំចូល ដែលនេះ ឆ្លុះបញ្ចាំងតាមរយៈការធ្លាក់ចុះ នៃបារ៉ូម៉ែត្រពាណិជ្ជកម្មទំនិញសកល ទៅត្រឹមពិន្ទុ ៩៩,៥ នៅខែវិច្ឆិកា ក្រោមពិន្ទុគោល ១០០ ខណៈដែល កំណត់ត្រានៅខែសីហា ស្មើនឹង ១១០,៤ ពិន្ទុ។

ទន្ទឹមនេះ អង្គការពាណិជ្ជកម្មពិភពលោក ក៏បានកត់សម្គាល់ពី បញ្ហាផ្គត់ផ្គង់(supply shock) ដែលរួមមាន ការកកស្ទះកំពង់ផែ(បណ្តាលមកពីការហក់ឡើងនៃតម្រូវការនាំចូល នៅពាក់កណ្តាលដើមឆ្នាំ) និងការរំខានផ្នែកផលិតកម្មនៃទំនិញមួយចំនួន(យានយន្ត និងឧបករណ៍ Semiconductor)។ បន្ថែមពីនេះទៀត តម្រូវការពាណិជ្ជកម្មទំនិញ ក៏ថមថយដែរ តាមរយៈការធ្លាក់ចុះនៃការបញ្ជាទិញសម្រាប់នាំចេញ។

គួរឱ្យកត់សម្គាល់ថា ការថយល្បឿននៃកំណើនពាណិជ្ជកម្មទំនិញសកលនេះ គឺស្របទៅនឹងការព្យាកររបស់អង្គការពាណិជ្ជកម្មពិភពលោក ដែលថា ទំហំពាណិជ្ជកម្មទំនិញសកល សម្រាប់ឆ្នាំ២០២១ នឹងមានកំណើន ១០,៨%។ ដោយឡែក ទស្សនវិស័យពាណិជ្ជកម្មសកល នៅតែប្រឈមជាមួយនឹងហានិភ័យការធ្លាក់ចុះ (downside risks) វិសមភាពក្នុងតំបន់ និងភាពទន់ខ្សោយនៃពាណិជ្ជកម្មសេវាកម្ម។ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ Reuters ចេញផ្សាយ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១*

## នាយកប្រតិបត្តិ JPMorgan លើកឡើងថា វិបត្តិបំណុលចិន ទំនងមិនជះឥទ្ធិពលទៅលើទីផ្សារពិភពលោក



*ប្រភព៖ South China Morning Post ២០២១*

នៅក្នុងទស្សនកិច្ចទៅកាន់ប្រទេសចិន លោក Jamie Dimon នាយកប្រតិបត្តិ JPMorgan Chase បាននិយាយទៅកាន់សារព័ត៌មាន South China Morning Post ថា បញ្ហារង្គោះរង្គើក្នុងវិស័យអចលនទ្រព្យចិន មិនទំនងជា ប៉ះទង្គិចខ្លាំងទៅកាន់ទីផ្សារពិភពលោក ដែលនឹងអាចបង្កជាវិបត្តិសកលនោះឡើយ។

ទន្ទឹមនេះដែរ លោកបានបន្តថា វិបត្តិបំណុលដែលបង្កដោយក្រុមហ៊ុនអចលនទ្រព្យនេះ មិនមែនជាបញ្ហាធំទេ ដែលប្រទេសចិនអាចចាត់វិធានការតាមរយៈការកែសម្រួលលើតម្លាភាព និងបទបញ្ញត្តិឱ្យកាន់តែល្អប្រសើរឡើង។

ដោយឡែក ធនាគារសហព័ន្ធអាមេរិក បានលើកឡើងថា បញ្ហាតានតឹងហិរញ្ញវត្ថុក្នុងប្រទេសចិន អាចនឹងប៉ះពាល់ទៅដល់ទីផ្សារហិរញ្ញវត្ថុពិភពលោក ដែលនឹងបង្កជាហានិភ័យចំពោះកំណើនសេដ្ឋកិច្ច ដោយសារតែការតភ្ជាប់ពាណិជ្ជកម្មចិន ជាមួយនឹងពិភពលោក ក៏ដូចជាទំហំសេដ្ឋកិច្ច និងទីផ្សារហិរញ្ញវត្ថុចិន។

ទោះជាយ៉ាងណាក៏ដោយ លោក Dimon មិនសង្កត់ធ្ងន់ទៅលើការព្រួយបារម្ភរបស់ធនាគារសហព័ន្ធអាមេរិកនោះឡើយ ដោយលោកបានកត់សម្គាល់ថា វិនិយោគិន និងម្ចាស់បំណុលអន្តរជាតិនៅតែមានការចាប់អារម្មណ៍ទៅលើប្រទេសចិន។ *ដោយ **ជា សិរីរតន៍***

*ប្រភព៖ South China Morining Post ចេញផ្សាយ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១*

## សេដ្ឋកិច្ចជប៉ុនធ្លាក់ចុះជាងការរំពឹងទុកដោយសារតែការផ្គត់ផ្គង់មានកង្វះខាត



*កំពង់ផែឧស្សាហកម្មនៅតូក្យូ ប្រទេសជប៉ុន នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ រូបភាព៖ REUTERS/Kim Kyung-Hoon*

សេដ្ឋកិច្ចរបស់ប្រទេសជប៉ុនមានការធ្លាក់ចុះជាងការរំពឹងទុកនៅក្នុងត្រីមាសទី៣ ដោយសារតែផលរំខាននៃការផ្គត់ផ្គង់របស់ពិភពលោកបានបង្ករការលំបាកដល់ការនាំចេញ និងផ្តល់ផលប៉ះពាល់ចំពោះការ

ចំណាយលើអាជីវកម្ម ខណៈដែលករណីឆ្លងជំងឺកូវីដ ១៩ ថ្មី បានធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍របស់អ្នកប្រើប្រាស់។ កន្លងមកអ្នកវិភាគជាច្រើនយល់ឃើញថា សេដ្ឋកិច្ចរបស់ជប៉ុននឹងងើបឡើងវិញក្នុងត្រីមាសនេះ ដោយរំពឹងថា ការឆ្លងរីករាលដាលជំងឺកូវីដ១៩ នឹងមានភាពធូរស្រាល។ ប៉ុន្តែផលិតកម្មរបស់ពិភពលោក បានបង្ករឱ្យសេដ្ឋកិច្ចជប៉ុនកាន់តែប្រឈមនឹងហានិភ័យ ដោយសារតែសេដ្ឋកិច្ចជប៉ុនពឹងផ្អែកខ្លាំងលើការនាំចេញ។

អ្នកវិភាគមួយចំនួនបាននិយាយថា សេដ្ឋកិច្ចជប៉ុនពឹងផ្អែកខ្លាំងលើឧស្សាហកម្មផលិតរថយន្ត។ បានសេចក្តីថា សេដ្ឋកិច្ចប្រទេសនេះងាយនឹងរងគ្រោះជាងប្រទេសផ្សេងទៀត ប្រសិនបើមានឧបសគ្គក្នុងវិស័យពាណិជ្ជកម្ម។ ម្យ៉ាងទៀត ទោះបីជាការឆ្លងរីករាលដាលកូវីដ១៩ មានភាពធូរស្រាលជាងមុនក្តី ប៉ុន្តែការងើបឡើងវិញរបស់សេដ្ឋកិច្ចជប៉ុនមានភាពយឺតយ៉ាវ ដោយសារតែការប្រើប្រាស់មានកំណើនយឺតនៅចុងខែកញ្ញា។ នាំឱ្យសេដ្ឋកិច្ចជប៉ុនធ្លាក់ចុះ ៣,០% ចាប់ពីខែកក្កដាដល់ខែកញ្ញា បន្ទាប់ពីបានកើនឡើងចំនួន ១,៥% នៅក្នុងត្រីមាសទីពីរ។ ផ្ទុយពីកំណើនសេដ្ឋកិច្ចរបស់ប្រទេសអភិវឌ្ឍមួយចំនួនដូចជា សេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកមានកំណើន ២,០% នៅក្នុងត្រីមាសទី៣ ដោយសារតែតម្រូវការមានការកើនឡើង។ ចំណែកប្រទេសចិនឯណោះវិញ វិស័យលក់រាយ និងប្រាក់ចំណូលរបស់រោងចក្រមានការកើនឡើងនៅក្នុងខែតុលា។ ខណៈដែល ផ.ស.ស របស់ជប៉ុនធ្លាក់ចុះខ្លាំងជាងការព្យាករណ៍ ០,៨% ដែលបានរំពឹងទុកថានឹងធ្លាក់ចុះក្នុងរង្វង់ប្រមាណ ០,២% ប៉ុណ្ណោះ។

ការប្រើប្រាស់នៅប្រទេសជប៉ុនចាប់ពីខែកក្កដា ដល់ខែកញ្ញាធ្លាក់ចុះ ១,១% បន្ទាប់ពីបានកើនឡើង ០,៩% នៅក្នុងអំលុងត្រីមាសមុន។ រីឯការចំណាយមូលធនវិញបានធ្លាក់ចុះ ៣,៨% បន្ទាប់ពីបានកើនឡើង ២,២% ក្នុងខែមេសាដល់ខែកក្កដា។ ចំណែកឯការសន្សំនៅក្នុងស្រុកស្មើនឹង ០,៩% ពិន្ទុនៃកំណើន ផ.ស.ស។ ខណៈដែលការនាំចេញធ្លាក់ចុះ ២,១% ដោយសារតែកង្វះការផ្គត់ផ្គង់បន្ទះឈីប និងដោយសារជួបឧបសគ្គនៅក្នុងខ្សែសង្វាក់ផលិតកម្ម។ រដ្ឋាភិបាលជប៉ុនបានប្រកាសបញ្ចេញទឹកប្រាក់ដល់ទៅរាប់សិបពាន់លានយ៉េន ដើម្បីទ្រទ្រង់សេដ្ឋកិច្ច។ ប៉ុន្តែអ្នកវិភាគមួយចំនួនយល់ថា ទឹកប្រាក់នេះប្រហែលជាមិនអាចមានផលប៉ះពាល់អ្វីដល់កំណើនសេដ្ឋកិច្ចក្នុងរយៈពេលខ្លីឡើយ ដោយសារតែគោលបំណងនៃការប្រើប្រាស់ថវិកានេះមានភាពមិនច្បាស់លាស់ និងមានទិសដៅចម្រុះពេក។

កន្លងមកអ្នកវិភាគរបស់សារព័ត៌មាន Reuters បានរំពឹងទុកថា នៅក្នុងត្រីមាសនេះសេដ្ឋកិច្ចរបស់ជប៉ុននឹងកើនឡើង ៥,១% ប្រចាំឆ្នាំ ព្រោះពួកគេគិតថា សកម្មភាពរបស់អ្នកប្រើប្រាស់ និងការផលិតរថយន្តនឹងកើនឡើង។ ប៉ុន្តែក្រុមហ៊ុនរបស់ជប៉ុននៅតែប្រឈមនឹងហានិភ័យ ដោយសារតែថ្លៃដើមកើនឡើងខ្ពស់ និងមានការរាំងស្ទះនៅក្នុងការផ្គត់ផ្គត់។ លោក លោក Takahide Kiuchi អតីតសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារជប៉ុន ដែលឥឡូវនេះកំពុងបម្រើការងារជាប្រធានសេដ្ឋវិទូនៅវិទ្យាស្ថានស្រាវជ្រាវ Nomura បាននិយាយថា ផ.ស.ស ពិត គឺជាកត្តាមួយដែលទទួលការជះឥទ្ធិពលពីអតិផរណា ដូចនេះវានឹងមិនអាចត្រលប់ទៅរកកម្រិតប្រក្រតីដូចមុនពេលមានជំងឺរាតត្បាតបានទេរហូតដល់ពាក់កណ្តាលឆ្នាំ២០២៣។ លោក Kiuchi បាននិយាយទៀតថា "*ដោយសារកំណើនសេដ្ឋកិច្ចរបស់ប្រទេសចិនមាន*

*ភាពយឺតយ៉ាវ បូករួមនឹងពិភពលោកជួបប្រទះឧបសគ្គនៅក្នុងការផ្គត់ផ្គង់ តម្លៃថាមពលកើនឡើង និងការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចរបស់បណ្ដាប្រទេសនៅលោកខាងលិចដែលកំពុងតែរងគ្រោះដោយអតិផរណា នឹងនាំឱ្យកំណើនសេដ្ឋកិច្ចរហូតដល់ពាក់កណ្ដាលឆ្នាំ២០២២ នឹងត្រូវបានកាត់បន្ថយ។ ម្យ៉ាងវិញទៀត ដោយសារការនាំចេញនៅតែមានសភាពធ្ងន់ធ្ងរ នាំឱ្យកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំរបស់ប្រទេសជប៉ុនក្នុងរយៈពេលមធ្យមទំនងជាទទួលរងនូវផលប៉ះពាល់ពី ១% ទៅ ២% នៅក្នុងត្រីមាសទីពីរនេះតទៅ ទោះបីជារដ្ឋាភិបាលព្យាយាមគិតគូរពីផលប៉ះពាល់ និងធ្វើការជំរុញសេដ្ឋកិច្ចយ៉ាងណាក៏ដោយ៕"*

*ដោយ* ***កញ្ញា វង្ស ច័ន្ទរស្មីដារា***

*ប្រភព៖ Reuters ចេញផ្សាយ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១*

## តម្លៃស្បៀងអាហារ បន្តឡើងថ្លៃខ្លាំងគួរឱ្យបារម្ភ



*ដោយ ៖ rfi.fr*

យោងតាមរបាយការណ៍របស់អង្គការស្បៀងអាហារ និងកសិកម្មពិភពលោក (FAO) នៅក្នុងខែតុលា កន្លងទៅតម្លៃស្បៀងអាហារ និងគ្រាប់ធញ្ញជាតិបានបន្តឡើងថ្លៃខ្លាំងគួរឱ្យព្រួយបារម្ភ។ តម្លៃនេះ បានកើនចំនួន៣% នៅក្នុងខែតុលា បើប្រៀបធៀបទៅនឹង ខែកញ្ញា។ នៅក្នុងកំឡុងពេលមួយឆ្នាំ តម្លៃស្បៀងអាហារបានឡើងចំនួន៣១,៣%។ តម្លៃស្បៀងអាហារ បានឡើងខ្លាំងជិតស្មើកម្រិតខ្ពស់បំផុត កាលពីខែកុម្ភៈ ឆ្នាំ២០១១។ នេះ បណ្ដាលមកការប្រមូលទិន្នផលគ្រាប់ធញ្ញជាតិបានចុះថយខ្លាំង នៅតាមប្រទេសមួយចំនួនដូចជានៅកាណាដា រុស្ស៊ី និង អាមេរិកជាដើម។

ក្រៅពីតម្លៃគ្រាប់ធញ្ញជាតិ នៅលើទីផ្សារអន្តរជាតិ តម្លៃប្រេងឆាចម្រាញ់ពីគ្រាប់ធញ្ញជាតិ ក៏បានឡើងតម្លៃចំនួន ៩,៦% ក្នុងរវាងមួយខែចុងក្រោយ ដែលជាកម្រិតតម្លៃខ្ពស់បំផុតមិនធ្លាប់មាន។ ប្រេងចំរាញ់ពីដូងប្រេង បានឡើងថ្លៃ៤ខែជាប់គ្នា ដោយសារតែមានការព្រួយបារម្ភ អំពីសមត្ថភាពផលិតនៅប្រទេសម៉ាឡេស៊ីបន្ទាប់ពីវិស័យនេះខ្វះកម្លាំងពលកម្ម ក្នុងវិបត្តិកូវីដ ១៩។ រីឯតម្លៃទំនិញធ្វើពីទឹកដោះគោ បានឡើងថ្លៃចំនួន ២,២% ក្នុងមួយខែចុងក្រោយ និង ១៥,៥% ក្នុងរវាងមួយឆ្នាំចុងក្រោយ។

ដោយឡែក តម្លៃសាច់សត្វ បានចុះថ្លៃ ប្រមាណជា 0,៧% បើប្រៀបធៀបទៅខែកញ្ញា គឺបានចុះ ចំនួន៣ខែជាប់គ្នាហើយ ដោយសារតែតម្រូវការក្នុងប្រទេសចិនបានធ្លាក់ចុះ។ តែយ៉ាងណាតម្លៃសាច់នៅតែខ្ពស់ លើសឆ្នាំមុន ចំនួនប្រមាណ ២២%។

ប៉ុន្តែ តម្លៃសាច់សត្វស្លាប ដូចជាសាច់មាន់ជាដើម បានកើនឡើងដោយសារតម្រូវការបានកើនឡើង និងមួយផ្នែកទៀត ដោយសារតែមានការព្យាករណ៍ថា ការផលិតនឹងមិនអាចឡើងចំនួនលើសនេះ ព្រោះបណ្ដាលមកពីតម្លៃចំណីសត្វ និងជំងឺផ្ដាសាយបក្សី។ ចំពោះតម្លៃស្ករវិញ បានចុះថយ១,៨% នៅក្នុងខែកញ្ញា បន្ទាប់ពីបានកើនតម្លៃប្រមាណជា ៦ខែជាប់គ្នា។

អង្គការ FAO បានព្យាករណ៍ថា ការប្រមូលទិន្នផលគ្រាប់ធុញ្ញជាតិ នៅក្នុងឆ្នាំ២០២១នេះ នឹងកើនឡើង និង តម្រូវការស្រូវសាឡី នៅទូទាំងពិភពលោក នឹង

កើនឡើងផងដែរ ក្នុងឆ្នាំ២០២១-២០២២ ដោយសារតែចំនួនប្រជាជនបានកើនឡើង៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ rfi.fr ចេញផ្សាយថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១។*

## តម្លៃប្រេងឆៅធ្លាក់ចុះ ខណៈមានការរំពឹងថា នឹងមានការកើនឡើងការផ្គត់ផ្គង់



*ដោយ ams.central*

ទីផ្សារប្រេងបានធ្លាក់ចុះក្នុងរយៈពេលបីសប្តាហ៍ចុងក្រោយនេះ ដោយសារកំណើនថ្លៃប្រាក់ដុល្លារ និងការរំពឹងថា រដ្ឋាភិបាលអាមេរិក អាចបញ្ចេញប្រេងពីស្តុកប្រេងរបស់ខ្លួន ដើម្បីទម្លាក់ថ្លៃប្រេង។ នៅថ្ងៃចន្ទដើមសប្តាហ៍នេះ តម្លៃប្រេងឆៅបានធ្លាក់ចុះ ព្រោះមានការរំពឹងថា នឹងមានការផ្គត់ផ្គង់កាន់តែកើនឡើង។

គួរបញ្ជាក់ថា កិច្ចសន្យាទិញលក់អនាគតសម្រាប់ប្រេងឆៅប្រភេទ Brent របស់អង់គ្លេស បានធ្លាក់ថ្លៃ ៦៣សេន ឬ០,៨% មកនៅត្រឹម៨១,៥៤ដុល្លារក្នុងមួយបារ៉ែល ស្របពេលដែលប្រេងឆៅប្រភេទ West Texas Intermediate (WTI) របស់សហរដ្ឋអាមេរិកបានធ្លាក់ថ្លៃ ៥៥សេន ឬ ០,៧% មកនៅត្រឹម ៨០,២៤ដុល្លារក្នុងមួយបារ៉ែល៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ ams.central ចេញផ្សាយថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១។*

## ប្រទេសផលិតមាសកំពូលទាំង១០ក្នុងលោក មាន១នៅអាស៊ាន



*ដោយ Kampucheathmey*

មាសជាវត្ថុជាតុកម្របំផុតក្នុងពិភពលោកនេះដែលបង្កើតបានចន្លោះ០,០០១ និង០,០០៦ផ្នែកក្នុងមួយលាននៃសំបកផែនដី។ ក្រុមប្រឹក្សាមាសពិភពលោក (WGC) ឱ្យដឹងថា ការផលិតរ៉ែមាសទូទាំងពិភពលោកកាលពីឆ្នាំ២០២០ បានចំនួន ៣ ៤៧៨,១តោន ដែលចំនួននេះធ្លាក់ចុះតិចតួចក្នុងរយៈពេលពីរឆ្នាំជាប់គ្នាបន្ទាប់ពីបានឡើងខ្ពស់កាលពីប៉ុន្មានឆ្នាំមុន។ វិបត្តិកូវីដ-១៩បានរួមចំណែកធ្វើឱ្យការផលិតមាសយឺតកាលពីឆ្នាំមុន ប៉ុន្តែយើងក៏កំពុងឃើញពីការថយចុះថវិកានៃការរុករកផងដែរ។

ប្រទេសអាហ្វ្រិកខាងត្បូង គឺជាប្រទេសឈានមុខគេមួយដែលបានផលិតមាសច្រើនបំផុតកាលពីឆ្នាំ១៩៧០ ដោយផលិតបានចំនួន១០០០តោន ប៉ុន្តែចាប់តាំងពីនោះមកបានថយចុះយ៉ាងខ្លាំង ហើយត្រូវបានធ្លាក់ចេញពីបញ្ជីផលិតមាសកំពូលទាំង១០លើលោក។ បន្ទាប់មកប្រទេសបេរ៉ូក៏បានបាត់មុខ ប៉ុន្តែលេចមុខប្រទេសថ្មីគឺ អ៊ូសបេគីស្ថាន និងប្រេស៊ីល ហើយហ្គាណាបានក្លាយជាប្រទេសតែមួយគត់មកពីអាហ្វ្រិកស្ថិតក្នុងចំណោមកំពូលទាំង១០។

ខាងក្រោមនេះ ជាសេចក្តីលំអិតពីប្រទេសកំពូលទាំង១០ដែលផលិតមាសច្រើនជាងគេបំផុតក្នុងពិភពលោក

កាលពីឆ្នាំ២០២០(ទិន្នន័យទាំងអស់ទទួលបានពី WGC គិតត្រឹមខែមិថុនាឆ្នាំ២០២១)។ ប្រទេសចិនដែលស្ថិតនៅចំណាត់ថ្នាក់លេខ១ជាអ្នកផលិត និងជាអ្នកប្រើប្រាស់។

**ទី១៖ ចិន ផលិតមាសបាន៣៦៨,៣តោន**

ជាច្រើនឆ្នាំកន្លងទៅហើយ ចិនបានកំពុងក្លាយជាប្រទេសផលិតមាសច្រើនជាងគេបំផុតក្នុងពិភពលោកស្មើនឹង១១%នៃការផលិតរ៉ែមាសទូទាំងពិភពលោក។ ទោះជាយ៉ាងណា ការផលិតបានធ្លាក់ពី៣៨៣តោនមកនៅត្រឹម៣៦៨តោនកាលពីឆ្នាំមុន បណ្ដាលមកពីគោលនយោបាយបរិស្ថានតឹងរឹងដែលដាក់ចេញដោយរដ្ឋាភិបាល។

**ទី២៖ រុស្ស៊ី ផលិតមាសបាន៣៣១,១តោន**

មាសនៅអឺរ៉ុបភាគច្រើនចេញមកពីរុស្ស៊ីដែលបានកំពុងកើនឡើងក្នុងការផលិតជារៀងរាល់ឆ្នាំគិតចាប់ពីឆ្នាំ២០១០មក។ នៅឆ្នាំ២០១៩ រុស្ស៊ីបានវ៉ារដាច់អូស្ត្រាលីដើម្បីឡើងមកឈរចំណាត់ថ្នាក់លេខ២ក្នុងនាមជាប្រទេសផលិតមាសច្រើនបំផុតក្នុងពិភពលោក។ រដ្ឋាភិបាលរុស្ស៊ីជាអតិថិជនធំបំផុតដែលបានទិញ២/៣នៃមាសដែលផលិតក្នុងស្រុកទាំងអស់។

**ទី៣៖ អូស្ត្រាលី ផលិតមាសបាន៣២៧,៨តោន**

អូស្ត្រាលីបានប្រកាសពីការកើនឡើងក្នុងការផលិតមាស៨ឆ្នាំជាប់គ្នា។ ឧស្សាហកម្មរ៉ែមាសផលិតបានជាងពាក់កណ្ដាលនៃការនាំចេញសរុបរបស់ប្រទេស និងបង្កើតបានប្រហែល៨%នៃផលិតផលក្នុងស្រុកសរុប។

**ទី៤៖ សហរដ្ឋអាមេរិក ផលិតមាសបាន១៩០,២តោន**

មាសជិត៨០%ផលិតនៅអាមេរិកគឺបានមកពីរដ្ឋ Nevada។ ប្រសិនបើរដ្ឋនេះជាប្រទេសវិញនោះ មានន័យថា វានឹងក្លាយជាប្រទេសផលិតមាសលំដាប់កំពូលទាំង១០មួយដែរ។

**ទី៥៖ កាណាដា ផលិតមាសបាន១៧០,៦តោន**

អណ្ដូងរ៉ែមាសធំបំផុតរបស់ប្រទេសនេះគឺ Canadian Malartic ដែលមានសហម្ចាស់ Yamana Gold និង Agnico Eagle។

**ទី៦៖ ហ្គាណា ផលិតមាសបាន១៣៨,៧តោន**

ហ្គាណាជាប្រទេសផលិតមាសធំជាងគេបំផុតនៅអាហ្វ្រិក ដោយបានយកឈ្នះអាហ្វ្រិកខាងត្បូងជាលើកដំបូងកាលពីឆ្នាំ២០១៩។ ឧស្សាហកម្មធំៗដូចជា AngloGold Ashanti និង Gold Fields បានផ្លាស់ប្ដូរការផ្ដោតអារម្មណ៍របស់ពួកគេពីអាហ្វ្រិកខាងត្បូងទៅហ្គាណាវិញដែលជាកន្លែងបញ្ញើមានតម្លៃទាប និងងាយស្រួលរុករក។

**ទី៧៖ ប្រេស៊ីល ផលិតមាសបាន១០៧តោន**

សកម្មភាពរុករករ៉ែមាសខុសច្បាប់ បានកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេល៦ឆ្នាំចុងក្រោយនេះ ទៅលើបេះដូងនៃព្រៃអាម៉ាហ្សូន។ លោកប្រធានាធិបតីប្រេស៊ីល បានជំរុញប្រទេសឱ្យអភិវឌ្ឍសេដ្ឋកិច្ចអាម៉ាហ្សូន និងទាញយកផលពីរ៉ែមាសដ៏សំបូរបែប។

**ទី៨៖ អ៊ូយបេគីស្ថាន ផលិតមាសបាន១០១,៦តោន**

នេះជាលើកដំបូងហើយដែលប្រទេសនេះផលិតមាសបានជាង១០០តោនក្នុងមួយឆ្នាំ។ ប្រទេសនេះមាន Muruntau ដែលជាអណ្ដូងរុករកមាសបើកចំហធំជាងគេបំផុតក្នុងពិភពលោក។

**ទី៩៖ ម៉ិកស៊ិក ផលិតមាសបាន១០១,៦តោន**

ទិន្នផលបានកើនឡើងពី៥០,៨តោនក្នុងឆ្នាំ២០០៨ ឡើងដល់កំពូលរបស់ខ្លួន១៣១តោនក្នុងឆ្នាំ២០១៥។

**ទី១០៖ ឥណ្ឌូណេស៊ី ផលិតមាសបាន១០០,៩តោន**

ឥណ្ឌូណេស៊ីជាកន្លែងដែលមានរ៉ែមាសធំជាងគេលំដាប់ទី២ក្នុងពិភពលោក និងអណ្ដូងរ៉ែមាសធំជាងគេបំផុតក្នុងលោកគឺ Grasberg ដោយគ្រប់គ្រងដោយ PT

Freeport Indonesia ហើយមានកម្មករដល់ទៅ២ម៉ឺននាក់។ ប្រទេសនេះផ្គត់ផ្គង់មាស៣%នៃការផ្គត់ផ្គង់មាសទូទាំងពិភពលោក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ kampucheathmeyបេញផ្សាយថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី២២ ខែវិច្ឆិកា ឆ្នាំ២០២១

- ឱនភាពពាណិជ្ជកម្ម ប្រទេសអេស្ប៉ាញបានកើនឡើងយ៉ាងខ្លាំង ក្នុងខែសីហា ឆ្នាំ 2021
- បំណុលរដ្ឋាភិបាលប្រទេសទួរគីបានកើនឡើងដល់ 2181100 TRY លាននៅក្នុងខែកញ្ញាពី 2041700 TRY លាននៅក្នុងខែសីហាឆ្នាំ 2021

ថ្ងៃអង្គារ ទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១

- សូចនាករវដ្តអាជីវកម្មក្នុងប្រទេសអាហ្វ្រិកខាងត្បូងបានកើនឡើង ក្នុងខែសីហា ឆ្នាំ 2021
- ការលក់រាយនៅម៉ិកស៊ិកបានធ្លាក់ចុះ ក្នុងខែសីហា ឆ្នាំ 2021 ធៀបនឹងខែមុន

ថ្ងៃពុធ ទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មរបស់ប្រទេសអាហ្សង់ទីនបានកើនឡើង ក្នុងខែកញ្ញា ឆ្នាំ 2021
- អត្រាអតិផរណាស្នូលពាក់កណ្តាលខែ ប្រទេសម៉ិកស៊ិកបានកើនឡើង នៅក្នុងខែកញ្ញាឆ្នាំ 2021

ថ្ងៃព្រហស្បតិ៍ ទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១

- ការចំណាយដើមទុនថ្មីសរុបនៅក្នុងប្រទេសអូស្ត្រាលីបានកើនឡើង ក្នុងរយៈពេល 3 ខែដល់ខែមិថុនា ឆ្នាំ 2021
- ផលិតផលក្នុងស្រុកសរុបរបស់ម៉ិកស៊ិកបានកើនឡើង ក្នុងត្រីមាសទីបីនៃឆ្នាំ 2021

ថ្ងៃសុក្រ ទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១

- ម៉ិកស៊ិកបានរាយការណ៍ពីឱនភាពពាណិជ្ជកម្មចំនួន 2.4 ពាន់លានដុល្លារក្នុងខែកញ្ញា ឆ្នាំ 2021 ពីអតិរេកចំនួន 4.4 ពាន់លានដុល្លារក្នុងខែដែលត្រូវគ្នានៃឆ្នាំ 2020
- ឱនភាពថវិការបស់រដ្ឋាភិបាលកាណាដាបានរួមតូចមកត្រឹម 9.83 ពាន់លាន CAD ក្នុងខែសីហា ឆ្នាំ 2021៕